ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

# តាងនាមប្រជារាស្ត្រខ្មែរ
## តុលាការកំពូល

សំណុំរឿងរដ្ឋប្បវេណី
លេខ: ១៨
ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៩
សាលដីកា
លេខ: ៨៣ "ញ"
ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២០

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នាសវនាការជាសាធារណៈ នៅថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជម្រះដូចខាងក្រោម:

១-ឯកឧត្តម [redacted] ប្រធាន
២-លោក ចៅក្រម
៣-លោក ចៅក្រម
៤-លោក ចៅក្រម
៥-លោក ចៅក្រម
៦-លោក ចៅក្រម
៧-លោកស្រី ចៅក្រម
៨-លោកស្រី ចៅក្រម
៩-លោកស្រី ចៅក្រម

ក្រឡាបញ្ជី

លោកស្រី [redacted]

តំណាងមហាអយ្យការ

ឯកឧត្តម [redacted] អគ្គព្រះរាជអាជ្ញារង

-ដើមចោទឈ្មោះ [redacted] គយ ភេទស្រី អាយុ ៦៣ឆ្នាំ ជាតិខ្មែរ [redacted] ។ (ដើមបណ្តឹងសាទុក្ខ)

-មានលោក [redacted] និងលោកស្រី [redacted] ជាមេធាវីតំណាងដោយអាណត្តិ ។



Scanned with CamScanner

-ចុងចម្លើយ [redacted] ចន្ថា ភេទប្រុស អាយុ៤៤ឆ្នាំ ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ន [redacted] ។ (ចុងបណ្តឹងសាទុក្ខ)

-មានលោក [redacted] ជាធារីតំណាងដោយអាណត្តិ ។

**<u>កម្មវត្ថុនៃបណ្តឹង</u>៖** -ប្តឹងទាមទារដីកេរ្តិ៍មរតក ។

## <u>អំពីអង្គហេតុ និងចំណុចទនាន</u>

**ក.<u>អំពីអង្គហេតុជាមូលហេតុនៃការទាមទារ</u>**

តាមពាក្យបណ្តឹងរបស់ដើមចោទឈ្មោះ [redacted] គយ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០២ ថា: ខ្លួនសុំប្តឹងពីឈ្មោះ [redacted] ចន្ថា ភេទប្រុស អាយុ២៦ឆ្នាំ និងឈ្មោះ [redacted] ចន្តន ភេទប្រុស អាយុ២០ឆ្នាំ ទីលំនៅ [redacted] ដើម្បីទាមទារការកាប់ទ្រព្យសម្បត្តិរបស់ខ្លួនវិញដូចខាងក្រោម៖

-ផ្ទះ ២ខ្នង ចង្ក្រានបាយ ១ខ្នង

-ដីភូមិ ដីស្រែចំនួន ៦០ អារ

-ដីចំការ ៣ហិចតា + ដំណាំគ្រប់មុខទទួលផល

-គោ ៣ ក្បាល (ញីមួយ,ឈ្មោលពីរ)

**បានឃើញសាលក្រមរដ្ឋប្បវេណីលេខ១១១ ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០២ របស់សាលាដំបូងខេត្តកំពត ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖**

១-ទទួលពាក្យបណ្តឹងរបស់ដើមចោទ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០២ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់។

២-ទ្រព្យសម្បត្តិមានផ្ទះ ២ខ្នង ផ្ទះបាយ ១ខ្នង ប្រក់ហ្វីប្រូ ដីភូមិប្រគល់ឱ្យឈ្មោះ [redacted] គយ គ្រប់គ្រង និងចាត់ចែងតាមច្បាប់ ឯដីចំការ ១កន្លែង ដីស្រែ១កន្លែង និងគោ ៣ក្បាល ត្រូវចែកជាពីរចំណែកស្មើគ្នា។

៣-បង្គាប់ឱ្យឈ្មោះ [redacted] ចន្ថា បង់ប្រាក់ប្រដាប់ក្តីតាមច្បាប់ និងបង់ពន្ធសមាមាត្រ១% លើតម្លៃនៃទ្រព្យសម្បត្តិទំនាស់ នៅពេលដែលសាលក្រមនេះចូលជាស្ថាពរ។

សាលក្រមនេះជំនុំជម្រះ និង ប្រកាសជាសាធារណៈចំពោះមុខគូភាគី សម្រេចបើកផ្លូវឧទ្ធរណ៍តាមកំណត់ច្បាប់។



Scanned with CamScanner

បានឃើញបណ្តឹងឧទ្ធរណ៍លេខ៦៥ ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០២ របស់ឈ្មោះ [redacted] ចន្ថា មិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ១១១ ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០២ របស់សាលាដំបូងខេត្តកំពត ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល។

**បានឃើញសាលដីការដ្ឋប្បវេណីលេខ ១០ "ខ" ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០០៧ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ:**

១-ទទួលបណ្តឹងឧទ្ធរណ៍លេខ ៦៥ ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០២ របស់ឈ្មោះ [redacted] ចន្ថា ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់។

២-បដិសេធសាលក្រមលេខ ១១១ ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០២ របស់តុលាខេត្តកំពត ចោលជាអសារបង់។

៣-ប្រគល់ទ្រព្យសម្បត្តិ ជាមត៌ករបស់មត៌កជនឈ្មោះ [redacted] លិ និង [redacted] ទ្រី មានផ្ទះ ២ខ្នង ប្រក់ហ្វីប្រូ ផ្ទះបាយ១ខ្នង ដីភូមិ ដីចំការ១កន្លែង ដីស្រែ១កន្លែង និងគោ ៣ ក្បាល ទៅឱ្យចុងចម្លើយឈ្មោះ [redacted] ចន្ថា កាន់កាប់តាមច្បាប់នៅពេលដែលសាលកដីកានេះចូលជាស្ថាពរ។

៤-រឹបអូសប្រាក់ប្រដាប់ក្តី គឺពន្ធចុះបញ្ជីក្តី និងពន្ធហ្វឹង ២.៥៥០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ចំនួន ៤៥០ រៀល ប្រាក់ប្រគល់ដីកាកោះ ៥.០០០ រៀល អាជ្ញាធរតុលាការ ៥.០០០ រៀល សរុប ១៣.០០០រៀល។ ប្រាក់នេះបានមកពីដើមបណ្តឹងឧទ្ធរណ៍ បានបង់រួចហើយ នៅពេលសាលដីកានេះចូលជាស្ថាពរ បង្គាប់ឱ្យឈ្មោះ [redacted] គយ បង់សងវិញ និងបង្គាប់ឱ្យដើមចោទ បង់ពន្ធសមាមាត្រា ១% លើតម្លៃជាក់ស្តែងនៃទ្រព្យសម្បត្តិទាំងអស់ ដែលសាលាឧទ្ធរណ៍បានសម្រេច។

សាលដីកានេះជំនុំជម្រះ និប្រកសាជាសាធារណៈចំពោះមុខដើមចោទ កំបាំងមុខចុងចម្លើយ បើកផ្លូវតវ៉ាតាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ៧៤ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ របស់ឈ្មោះ [redacted] គយ ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ១០ "ខ" ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០០៧ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល។

**បានឃើញសាលដីការដ្ឋប្បវេណីលេខ ១៣១ "ច" ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០០៩ របស់តុលាការកំពូល ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ:**

១-ទទួលបណ្តឹងសាទុក្ខលេខ ៧៤ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ របស់លោកស្រី [redacted] គយ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់។

២-ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ ១០ “ខ” ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០០៧ របស់សាលាឧទ្ធរណ៍ទាំងមូល។

៣-បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ ០៨ “ថ្មី” ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៧ របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជម្រះជាថ្មីឡើងវិញ។

៤-ប្រាក់ប្រដាប់ក្តីជាន់តុលាការកំពូលជាបន្ទុករបស់ចុងចម្លើយ។

៥-សាលដីកានេះប្រកាសសវនាការជាសាធារណៈ នៅថ្ងៃទី០៦ ខែមេសា ឆ្នាំ២០០៩ ។

**បានឃើញសាលដីការដ្ឋប្បវេណីលេខ ០៤ “ឈ” ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១០ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ:**

១-ទទួលជំនុំជម្រះជាថ្មីឡើងវិញ តាមអំណាចសាលដីការដ្ឋប្បវេណីលេខ ១៣១ “ច” ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០០៩ របស់តុលាការកំពូល។

២-ទ្រព្យសម្បត្តិមានផ្ទះ ២ខ្នង ផ្ទះបាយ ១ខ្នង ប្រក់ហ្វ៊ីប្រូ និងដីភូមិ ប្រគល់ឱ្យឈ្មោះ [redacted] ចន្ថា គ្រប់គ្រង និងកាន់កាប់តាមច្បាប់តទៅ ។ ចំណែកដីស្រែមួយកន្លែង និងដីចំការមួយកន្លែង និងគោចំនួន ៣ក្បាល ត្រូវចែកជាពីរចំណែកស្មើគ្នា។

៣-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់គូភាគី។

៤-សាលដីកានេះ ប្រកាសជាសាធារណៈ នៅថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១០។

បានឃើញបណ្តឹងសាទុក្ខលេខ២៤៩ ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១១ របស់ឈ្មោះ [redacted] គយ ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ០៤ “ឈ” ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១០ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល។

**ខ.<u>អំពីសេចក្តីថ្លែងការណ៍របស់គូភាគី</u>**

**-បានស្តាប់សេចក្តីថ្លែងការណ៍របស់អ្នកស្រី [redacted] គយ នាពេលទាញហេតុផលដោយផ្ទាល់មាត់ថា៖** ដីភូមិនោះ គឺជាដីកេរ្តិ៍របស់ម្តាយខ្លួនតាំងពីសង្គមចាស់ ហើយនៅពេលដែលបែករបបប៉ុលពត ខ្លួន និងម្តាយរបស់ខ្លួនបានទៅរស់នៅលើដីភូមិនោះវិញ ហើយចំពោះផ្ទះដែលបានសង់នៅលើដីនោះ គឺខ្លួនជាអ្នកចេញលុយសង់។

**សំណូមពរ៖** សុំឱ្យតុលាការបែងចែកដីស្រែ និងដីចំការពាក់កណ្តាលម្នាក់ និងសុំប្រគល់ផ្ទះ២ខ្នងមកឱ្យខ្លួនកាន់កាប់ជាម្ចាស់កម្មសិទ្ធិរបស់ខ្លួនផ្ទាល់។



Scanned with CamScanner

-បានស្តាប់សេចក្តីថ្លែងការណ៍របស់លោកស្រី [redacted] មេធាវីតំណាងដោយអាណត្តិឱ្យ**ដើមចោទថា៖** ចាប់តាំងពីឆ្នាំ១៩៧៩ ពេលដែលបែករបបប៉ុលពត កូនក្តីខ្លួន និងឪពុកឈ្មោះ [redacted] លិ ម្តាយឈ្មោះ [redacted] ទ្រី បានមករស់នៅទីតាំងដីទំនាស់។ នៅឆ្នាំ១៩៨២ កូនក្តីខ្លួន និងម្តាយឈ្មោះ [redacted] ទ្រី បានយកឈ្មោះ [redacted] ចន្ថា និងឈ្មោះ [redacted] ចន្ថន មករស់នៅជាមួយ និងចិញ្ចឹមមើលថែទាំរហូត។ លុះក្រោយពេលឪពុកម្តាយកូនក្តីខ្លួនស្លាប់ ឈ្មោះ [redacted] ចន្ថា មិនឱ្យកូនក្តីខ្លួនរស់នៅលើដី និងផ្ទះទំនាស់នោះទេ។ នៅក្នុងឆ្នាំ១៩៩៧ ក៏មានកំណត់ហេតុបែងចែកដីស្រែ និងដីភូមិឱ្យកូនក្តីខ្លួនផងដែរ។

**សំណូមពរ៖** សុំឱ្យតុលាការប្រគល់ផ្ទះពីខ្ទងមកឱ្យកូនក្តីខ្លួន និងដីស្រែ ដីចំការ ចែកជាពីរចំណែកស្មើគ្នា។

**-បានស្តាប់សេចក្តីថ្លែងការណ៍របស់លោក [redacted] មេធាវីតំណាងដោយអាណត្តិឱ្យដើមចោទថា៖** ចំពោះកំណត់ហេតុ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ១៩៩៧ គឺបានបញ្ជាក់អំពីការបែងចែកដីទ្រព្យសម្បត្តិនេះរួចហើយ។ ដូច្នេះសុំឱ្យចៅក្រមប្រឹក្សាមេត្តាពិនិត្យ និងសម្រេច។

**-បានស្តាប់សេចក្តីថ្លែងការណ៍របស់លោក [redacted] មេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយថា៖** ទ្រព្យសម្បត្តិរួមរបស់ក្រុមគ្រួសារលោកតា [redacted] លិ គឺកើតចេញពីការប្រគល់ជូនពីរដ្ឋជាលើកដំបូង ដែលពេលនោះរដ្ឋចែកឱ្យគិតទៅតាមចំនួនសមាជិក និងក៏មិនមែនជាទ្រព្យដែលកើតចេញពីចំណងអាពាហ៍ពិពាហ៍របស់លោកតា [redacted] លិ និងលោកយាយ [redacted] ទ្រី នោះឡើយ។ យោងតាមមាត្រា២ នៃអនុក្រឹត្យលេខ០៦ អនក្រ ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ១៩៨៥។

នៅក្នុងឆ្នំ១៩៩៧ លោកស្រី [redacted] គយ បានដាក់ពាក្យបណ្តឹងទាមទារទ្រព្យមតក៏របស់លោកយាយ [redacted] ទ្រី ហើយនៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ១៩៩៧ លោកតា [redacted] លិ បានដាក់ពាក្យបណ្តឹងតវ៉ានឹងពាក្យបណ្តឹងរបស់លោកស្រី [redacted] គយ ចូលសាលាស្រុកកំពត។ តាំងពីថ្ងៃនោះមកលោកស្រី [redacted] គយ មិនបានបន្តប្តឹងទៅតុលាការនោះឡើយ ហើយទ្រព្យសម្បត្តិទាំងអស់ស្ថិតក្រោមការគ្រប់គ្រងរបស់លោកតា [redacted] លិ លោក [redacted] ចន្ថា និងលោក [redacted] ចន្ថន។ បើគិតពីថ្ងៃទី០៦ ខែមិថុនា ឆ្នាំ១៩៩៥ ដែលលោកយាយ [redacted] ទ្រី ទទួលមរណភាពរហូតដល់ថ្ងៃលោកស្រី [redacted] គយ ដាក់ពាក្យបណ្តឹងទាមទារមកតុលាការនៅថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០២ គឺមានរយៈពេលជាង០៦ឆ្នាំ ដែលនាំឱ្យលោកស្រី [redacted] គយ ផ្តាច់សិទ្ធិក្នុងការទាមទារមត៌ករបស់លោកយាយ [redacted] ទ្រី។

សំណូមពរ៖ សុំតម្កល់សាលដីការដ្ឋប្បវេណីលេខ០៤ “ឈ” ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១០ របស់សាលាឧទ្ធរណ៍។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមទទួលបញ្ហា



Scanned with CamScanner

-ក្រោយពីបានស្តាប់យោបល់របស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីថ្លែងការណ៍របស់ដើមចោទឈ្មោះ [redacted] គយ និងសេចក្តីសន្និដ្ឋានរបស់មេធាវីតំណាងដោយអាណត្តិឱ្យគូភាគី

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

១-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ២៤៩ ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១១ របស់ឈ្មោះ [redacted] គយ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើកយករឿងនេះមកជំនុំជម្រះបានតាមមាត្រា ២៨៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី និងមាត្រា ៦២ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ។

២-យល់ឃើញថា នាពេលសវនាការនៅតុលាការកំពូលនេះ ដើមចោទឈ្មោះ [redacted] គយ ដែលជាម្ចាស់បណ្តឹងសាទុក្ខបានលើកឡើងថា ចំពោះសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍ដែលបានសម្រេចបែងចែកដីស្រែមួយកន្លែង និងដីចំការមួយកន្លែង និងគោចំនួនបីក្បាលជាពីរចំណែកស្មើគ្នានោះ ខ្លួនសុខចិត្តយល់ព្រមទទួលយក ប៉ុន្តែចំពោះដីភូមិដែលមានផ្ទះពីរខ្នង ផ្ទះបាយមួយខ្នងប្រក់ហ្វីប្រូនៅលើនោះ គឺខ្លួនមិនព្រមប្រគល់ទៅឱ្យឈ្មោះ [redacted] ចន្ថា នោះទេ ពីព្រោះថា៖

-ដីភូមិនោះ គឺជាដីកេរ្តិ៍របស់ម្តាយខ្លួនតាំងពីសង្គមចាស់ ហើយនៅពេលដែលបែករបបប៉ុលពត ខ្លួន និងម្តាយរបស់ខ្លួន បានទៅរស់នៅលើដីភូមិនោះវិញ ហើយចំពោះផ្ទះដែលបានសង់នៅលើដីនោះ គឺខ្លួនជាអ្នកចេញលុយសង់។

-ខ្លួនគឺជាកូនបង្កើតតែម្នាក់គត់របស់យាយ [redacted] ទ្រី និងលោកតា [redacted] លិ។ យោងតាមមាត្រា ១១៥៦ នៃក្រមរដ្ឋប្បវេណី "កូនរបស់មតកជនត្រូវក្លាយជាសន្តតិជន ដែលមានលំដាប់ទី១"។ ចំពោះឈ្មោះ [redacted] ចន្ថា និងឈ្មោះ [redacted] ចន្ថន គឺជាក្មួយរបស់ខ្លួន ដែលត្រូវបានម្តាយខ្លួន និងខ្លួន យកមករស់នៅជាមួយ និងចិញ្ចឹមមើលថែទាំ ក្រោយឪពុកម្តាយរបស់ឈ្មោះ [redacted] ចន្ថា និងឈ្មោះ [redacted] ចន្ថន ស្លាប់ចោលទៅ។

ឆ្លើយតបនឹងដើមចោទនេះ មេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយឈ្មោះ [redacted] ចន្ថា បានថ្លែងថា៖

-ដីភូមិដែលមានផ្ទះពីរខ្នង ផ្ទះបាយមួយខ្នងប្រក់ហ្វីប្រូនៅលើនោះ មិនមែនជាទ្រព្យដោយឡែករបស់លោកយាយ [redacted] ទ្រី ទេ ពីព្រោះ កម្មសិទ្ធិលើដីធ្លីពីសង្គមចាស់ ត្រូវបានច្បាប់កម្ពុជាលែងទទួលស្គាល់ហើយ។ ក្រោយពីបែករបបប៉ុលពតមក លោកតា [redacted] លិ និងលោកយាយ [redacted] ទ្រី បានមករស់នៅលើដីភូមិនេះទាំងអស់គ្នា ហើយលោកតា [redacted] លិ និងលោកយាយ [redacted] ទ្រី បានដាក់ពាក្យសុំកាន់កាប់



Scanned with CamScanner

ដីភូមិនេះរួមគ្នាទៀតផង ដូច្នេះដីភូមិនេះ គឺជាទ្រព្យសម្បត្តិរួមរបស់ក្រុមគ្រួសារលោកតា [redacted] លិ។ ចំពោះ ការអះអាងថា ផ្ទះដែលសង់នៅលើដីភូមិនោះ ឈ្មោះ [redacted] គយ ជាអ្នកសង់នោះ គឺពុំមានភស្តុតាង និងមូលដ្ឋានទាមទារឱ្យបានច្បាស់លាស់ទេ។

-លោកស្រី [redacted] គយ មិនមែនជាកូនបង្កើតរបស់លោកតា [redacted] លិ និងលោកយាយ [redacted] ទ្រី ទេ ប៉ុន្តែលោកស្រី [redacted] គយ គឺជាកូនបង្កើតរបស់លោកយាយ [redacted] ទ្រី និងត្រូវជាកូនចុងរបស់លោកតា [redacted] លិ ដូច្នេះលោកស្រី [redacted] គយ អាចប្តឹងទាមទារត្រឹមតែពាក់កណ្តាលនៃចំណែកទ្រព្យរបស់លោកយាយ [redacted] ទ្រី តែប៉ុណ្ណោះ។ ចំពោះឈ្មោះ [redacted] ចន្ថា និងឈ្មោះ [redacted] ចន្ទួន ត្រូវបានលោកតា [redacted] លិ និងលោកយាយ [redacted] ទ្រី យកមកចិញ្ចឹមតាំងតែពីដើមឆ្នាំ១៩៨២ និងដោយបានចុះឈ្មោះនៅក្នុងសៀវភៅគ្រួសារដោយដាក់ថាជាកូន។ ដូច្នេះយោងតាមច្បាប់ឈ្មោះ [redacted] ចន្ថា និងឈ្មោះ [redacted] ចន្ទួន គឺជាសន្តតិជនលំដាប់ទី១ ដែលត្រូវទទួលបានមត៌ករបស់លោកតា [redacted] លិ និងលោកយាយ [redacted] ទ្រី។

-លោកស្រី [redacted] គយ បានដាក់ពាក្យបណ្តឹងទាមទារទ្រព្យរបស់លោកយាយ [redacted] ទ្រី នៅឆ្នាំ១៩៩៧ ម្តងហើយ ហើយនៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ១៩៩៧ លោកតា [redacted] លិ បានដាក់ពាក្យបណ្តឹងតវ៉ាទៅនឹងពាក្យបណ្តឹងរបស់លោកស្រី [redacted] គយ ដូចសាលាស្រុកកំពត តាំងតែពីថ្ងៃនោះមកលោកស្រី [redacted] គយ មិនបានប្តឹងទៅតុលាការទៀតឡើយ។ ហើយទ្រព្យសម្បត្តិទាំងអស់ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់លោកតា [redacted] លិ លោក [redacted] ចន្ថា និងលោក [redacted] ចន្ទួន។ បើគិតពីថ្ងៃទី០៦ ខែមិថុនា ឆ្នាំ១៩៩៥ ដែលលោកយាយ [redacted] ទ្រី ទទួលមរណភាពរហូតដល់ថ្ងៃប្តឹងទាមទារដែលលោកស្រី ទ្រី គយ ដាក់ពាក្យបណ្តឹងមកតុលាការនៅថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០២ គឺមានរយៈពេល៦ឆ្នាំ និង១២ថ្ងៃ កន្លងហួសមកហើយ បានន័យថាលោកស្រី [redacted] គយ បានថ្លោះសិទ្ធិនៅក្នុងការប្តឹងទាមទារមត៌ករបស់លោកយាយ [redacted] ទ្រី ហើយបើយោងតាមច្បាប់ភូមិបាលឆ្នាំ២០០១ ត្រង់មាត្រា៧៩ និងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ត្រង់មាត្រា ១១៤៥ មាត្រា១១៤៦ មាត្រា ១២៤៨ និងមាត្រា១៣០៤។

-នៅពេលដែលលោកស្រី [redacted] គយ ដាក់ពាក្យបណ្តឹងទៅកាន់លោកអភិបាលស្រុកកំពត់នោះ លោកតា [redacted] លិ បានបញ្ជាក់យ៉ាងច្បាស់នៅក្នុងកំណត់ហេតុ ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ១៩៩៧ ថា ទ្រព្យសម្បត្តិសព្វថ្ងៃអាចចែកបានតែមនុស្សដែលជាសមាជិកក្នុងគ្រួសារចំនួន៥នាក់ មិនរាប់ឈ្មោះ [redacted] សុភី ឬឈ្មោះ [redacted] គយ នេះទេ ដែលនេះប្រៀបដីដូចជា ឆន្ទៈរបស់សពលោកតា [redacted] លិ ផងដែរ។

-ម្យ៉ាងវិញទៀត តុលាការអង្គសេចក្តីពុំបានពិចារណាទៅលើពាក្យសុំចូលជាភាគីរបស់ឈ្មោះ [redacted] ចន្ទួន ដែលបានដាក់ពាក្យបណ្តឹងតាំងតែពីនៅដំណាក់កាលសាលាឧទ្ធរណ៍លើកទី១ម្តេះ នៅថ្ងៃទី២៨ ខែមេសា ឆ្នាំ២០០៥ ដើម្បីសុំចូលជាភាគីមួយនៅក្នុងសំណុំរឿងក្តីទាក់ទងនឹងការប្តឹងទាមទារទ្រព្យសម្បត្តិ

របស់អ្នកស្រី [redacted] គយ នេះ។ ហេតុដូច្នេះ ខ្លួនសំណូមពរ សុំឱ្យតុលាការកំពូលពិចារណាអំពីចំណែកមរតក របស់ឈ្មោះ [redacted] ចន្តួន ផងដែរ និងសម្រេចច្រានចោលបណ្តឹងសាទុក្ខរបស់ដើមចោទឈ្មោះ [redacted] គយ។

-យល់ឃើញថា ការលើកឡើងរបស់ដើមចោទ មេធាវីតំណាងដោយអាណត្តិឱ្យភាគីដើមចោទ និងមេធាវីតំណាងដោយអាណត្តិឱ្យភាគីចុងចម្លើយខាងលើនេះ ពុំត្រឹមត្រូវទេ ពីព្រោះថា៖

-ក្រោយពីលោកយាយ [redacted] ទ្រី បានទទួលមរណភាពនៅឆ្នាំ១៩៩៦ ហើយលោកតា [redacted] លិ បានទទួលមរណភាពនៅឆ្នាំ២០០១ បានបន្សល់ទុកនូវទ្រព្យសម្បត្តិមួយចំនួនរួមមាន ដីភូមិមួយកន្លែង ដែលមានផ្ទះពីរខ្នង និងចង្ក្រានបាយមួយខ្នង ដីស្រែមួយកន្លែង ដីចំការមួយកន្លែង និងគោចំនួន៣ក្បាល ហើយក្នុងចំណោមទ្រព្យសម្បត្តិទាំងនេះ ត្រូវបានសាលាឧទ្ធរណ៍ប្រគល់ដីភូមិដែលមានផ្ទះពីរខ្នង និងចង្ក្រានបាយប្រក់ហ្វីប្រូ ឱ្យទៅឈ្មោះ [redacted] ចន្ថា គ្រប់គ្រង និងកាន់កាប់តាមច្បាប់ ចំណែកឯដីស្រែមួយកន្លែង និងដីចំការមួយកន្លែង គោចំនួន៣ក្បាល ត្រូវចែកជាពីរចំណែកស្មើគ្នារវាងដើមចោទឈ្មោះ [redacted] គយ និង ចុងចម្លើយឈ្មោះ [redacted] ចន្ថា។

ក្នុងចំណោមទ្រព្យសម្បត្តិដែលសាលាឧទ្ធរណ៍បានធ្វើការបែងចែកខាងលើនេះ ឈ្មោះ [redacted] គយ សុខចិត្តចំពោះការបែងចែក ដីស្រែមួយកន្លែង ដីចំការមួយកន្លែង និងគោចំនួន៣ក្បាល ជាពីរចំណែកស្មើគ្នា តែមិនសុខចិត្តនឹងការសម្រេចប្រគល់ទ្រព្យសម្បត្តិដែលជាដីភូមិដែលមានផ្ទះពីរខ្នង និងចង្ក្រានបាយប្រក់ ហ្វីប្រូ ទៅឱ្យឈ្មោះ [redacted] ចន្ថា ទេ។ ការសម្រេចសេចក្តីនេះ ឈ្មោះ [redacted] ចន្ថា ដែលជាចុងចម្លើយមិនបាន ប្តឹងសាទុក្ខមកកាន់តុលាការកំពូលទេ។

-ចំពោះការមិនសុខចិត្តរបស់ឈ្មោះ [redacted] គយ ទៅនឹងការសម្រេចប្រគល់ទ្រព្យសម្បត្តិដែលជាដីភូមិ ដែលមានផ្ទះពីរខ្នង និងចង្ក្រានបាយប្រក់ហ្វីប្រូទៅឱ្យឈ្មោះ [redacted] ចន្ថា នោះ តុលាការកំពូលយល់ឃើញ ថា ឈ្មោះ [redacted] គយ មិនមែនជាកូនបង្កើតរបស់លោកតា [redacted] លិ និងលោកយាយ [redacted] ទ្រី ទេ គឺឈ្មោះ [redacted] គយ ជាកូនបង្កើតរបស់លោកយាយ [redacted] ទ្រី ដូច្នេះ ឈ្មោះ [redacted] គយ ត្រូវជាកូនចុងរបស់លោកតា [redacted] លិ។ ចំពោះឈ្មោះ [redacted] ចន្ថា និងឈ្មោះ [redacted] ចន្ថន ថ្វីត្បិតតែត្រូវជាក្មួយរបស់ឈ្មោះ [redacted] គយ ពិតប្រាកដមែន ប៉ុន្តែឈ្មោះ [redacted] ចន្ថា និងឈ្មោះ [redacted] ចន្ថន នេះត្រូវបានលោកតា [redacted] លិ និងលោកយាយ [redacted] ទ្រី យកមកចិញ្ចឹមតាំងតែពីឆ្នាំ១៩៨២ មកម្ល៉េះ ក្រោយពីឪពុកម្តាយរបស់ឈ្មោះ [redacted] ចន្ថា និងឈ្មោះ [redacted] ចន្ថន បានទទួលមរណភាព។ ហើយក្រោយមកនៅឆ្នាំ១៩៩៩ លោកតា [redacted] លិ បានចុះឈ្មោះ [redacted] ចន្ថា និងឈ្មោះ [redacted] ចន្ថន នៅក្នុងសៀវភៅគ្រួសារ ដោយដាក់ថា ជាកូន និងជាសមាជិកក្នុងគ្រួសារ ហើយឈ្មោះ [redacted] ចន្ថា និងឈ្មោះ [redacted] ចន្ថន នេះបានរស់នៅជាមួយលោកតា និងលោកយាយនៅលើ

ដីភូមិ និងផ្ទះនោះ តាំងតែពីឆ្នាំ១៩៨២ រហូតដល់បច្ចុប្បន្ន និងបានមើលថែទាំលោកតា និងលោកយាយ រហូតដល់អ្នកទាំងពីរទទួលមរណភាព។

ដូច្នេះយោងតាមមាត្រា១១៥៦ នៃក្រមរដ្ឋប្បវេណី សន្តតិជនដែលមានលំដាប់ទី១ គឺជាកូន មិនថាកូនបង្កើត ឬកូនសុំនោះទេ តែមិនមែនជាកូនចុងនោះទេ។ ឈ្មោះ [redacted] ចន្ថា និងឈ្មោះ [redacted] ចន្ថន ដែលត្រូវជាកូនចិញ្ចឹមរបស់លោកតា [redacted] លិ និងលោកយាយ [redacted] ទ្រី គឺជាសន្តតិជនដែលមានលំដាប់ទី១។ ដោយឡែកឈ្មោះ [redacted] គយ ដែលត្រូវជាកូនរបស់លោកយាយ [redacted] ទ្រី និងត្រូវកូនចុងរបស់លោកតា [redacted] លិ មិនមែនជាសន្តតិជនដែលមានលំដាប់ទី១ នៃការទទួលមត៌ករបស់លោកតា [redacted] លិ និងលោកយាយ [redacted] ទ្រី ទេ។ ឈ្មោះ [redacted] គយ គប្បីទទួលបានតែចំណែកពាក់កណ្ដាលនៃទ្រព្យរបស់សពលោកយាយ [redacted] ទ្រី តែប៉ុណ្ណោះ។ ម្យ៉ាងវិញទៀត យោងតាមចម្លើយរបស់សាក្សីឈ្មោះ [redacted] សីហា និងតាមការទទួលស្គាល់របស់ឈ្មោះ [redacted] គយ គឺឈ្មោះ [redacted] គយ ត្រូវបានលោកយាយ [redacted] ទ្រី និងលោកតា [redacted] លិ ធ្វើការបែងចែកនូវទ្រព្យសម្បត្តិមួយចំនួនរួចហើយ ដែលមានដូចជា ដីស្រែ រោងម៉ាស៊ីនកិនស្រូវ និងដីភូមិមួយកន្លែងទៀតឱ្យទៅឈ្មោះ [redacted] គយ។ ហើយម្យ៉ាងវិញទៀត ការសម្រេចសេចក្ដីរបស់សាលាឧទ្ធរណ៍លើកទី២នេះទៀតសោត ក៏បានបែងចែកចំណែកដីស្រែមួយកន្លែង និងដីចំការមួយកន្លែង និងគោចំនួន៣ក្បាល ជាពីរចំណែកស្មើគ្នាឱ្យឈ្មោះ [redacted] ចន្ថា និងឈ្មោះ [redacted] គយ ថែមទៀតផងដែរ។

ដូច្នេះឃើញថា ការទាមទាររបស់ឈ្មោះ [redacted] គយ ដែលសូមឱ្យប្រគល់ដីភូមិ ដែលមានផ្ទះពីរខ្នង និងផ្ទះបាយមួយខ្នងបន្ថែមពីលើចំណែកដែលខ្លួនទទួលបានហើយនោះ គឺជាការមិនត្រឹមត្រូវទេ។

៣-យល់ឃើញថា ចំពោះពាក្យបណ្ដឹងសុំចូលជាភាគីរបស់ឈ្មោះ [redacted] ចន្ថន កាលពីថ្ងៃទី២៨ ខែមេសា ឆ្នាំ២០០៥ តាំងតែពីនៅតំណាក់កាលសាលាឧទ្ធរណ៍លើកទី១ ហើយដែលសាលាឧទ្ធរណ៍ពុំបានធ្វើការសម្រេចសេចក្ដីនោះ តុលាការកំពូលពុំមានសមត្ថកិច្ចលើកយកពាក្យបណ្ដឹងនេះមកពិចារណាទេ។ ក៏ប៉ុន្តែដោយហេតុថា សាលាឧទ្ធរណ៍មិនទាន់បានធ្វើការសម្រេចសេចក្ដីទៅលើចំណុចនេះនៅឡើយ ដូច្នេះមិនធ្វើឱ្យឈ្មោះ [redacted] ចន្ថន បាត់បង់សិទ្ធិក្នុងការទាមទារឱ្យតុលាការអង្គសេចក្ដីជំនុំជម្រះឡើងវិញត្រង់ចំណុចនេះទេ។

៤-យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ០៤ "ឈ" ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១០ របស់សាលាឧទ្ធរណ៍ដែលបានសម្រេចសេចក្ដីមកនេះ ត្រឹមត្រូវតាមច្បាប់ហើយ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្ដី

១-ច្រានចោលបណ្ដឹងសាទុក្ខលេខ ២៤៩ ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១១ របស់ឈ្មោះ [redacted] គយ ។

២-តម្កល់សាលដីការដ្ឋប្បវេណីលេខ ០៤ "ឈ" ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១០ របស់សាលាឧទ្ធរណ៍ ។

៣-ប្រាក់ប្រដាប់ក្តីជាន់តុលាការកំពូលជាបន្ទុករបស់ភាគីដើមចោទឈ្មោះ ទ្រី គយ។

សាលដីកានេះទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០ និងប្រកាសជាសាធារណៈនៅថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២០។

| | | |
|---|---|---|
| ឯកឧត្តម | [redacted] | ប្រធាន |
| លោក | | ចៅក្រម |
| លោក | | ចៅក្រម |
| លោក | | ចៅក្រម |
| លោក | | ចៅក្រម |
| លោក | | ចៅក្រម |
| លោកស្រី | | ចៅក្រម |
| លោកស្រី | | ចៅក្រម |
| លោកស្រី | | ចៅក្រម |
| លោកស្រី | | ក្រឡាបញ្ជី |

---

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម។

ថ្ងៃចន្ទ ១រោច ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ មីនា ឆ្នាំ២០២០

**ក្រឡាបញ្ជី**

[redacted]

បានឃើញ

ថ្ងៃចន្ទ ១រោច ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ មីនា ឆ្នាំ២០២០

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

*មានរូបមន្តអនុវត្តនៅខាងក្រោយ*